# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ២៦៤០ មស. ៧៩៣

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១៥

## សេចក្ដីជូនដំណឹង

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនសិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងធម្មការនិងសាសនា និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជូនដំណឹងដល់បេក្ខជនទាំងពីរភេទដែលបានបំពេញសំណុំបែបបទសុំសិទ្ធិប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័ន ទាំងប្រាំពីរ សម្រាប់ក្របខណ្ឌឆ្នាំ២០១៥ ដូចខាងក្រោម៖

**១- សម័យប្រឡង នៅពេលព្រឹក ថ្ងៃ អាទិត្យ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥**

**មណ្ឌលប្រឡង៖** វិទ្យាល័យព្រះស៊ីសុវត្ថិ (រាជធានីភ្នំពេញ)

☞ **ម៉ោង ០៦ : ០០ នាទី ដល់ ម៉ោង ០៦ : ៣០ នាទី**

- គ្រប់អនុគណៈកម្មការ និងបេក្ខជនទាំងអស់ត្រូវមកដល់មណ្ឌលប្រឡង

☞ **ម៉ោង ០៦ : ៤៥ នាទី ដល់ ម៉ោង ០៧ : ០០ នាទី**

- អនុក្សរហៅឈ្មោះបេក្ខជនចូលបន្ទប់ ប្រកាសបទបញ្ញត្តិ ចែកសន្លឹកកិច្ចការដល់បេក្ខជន និងស្រង់វត្តមាន

☞ **ម៉ោង ០៧ : ៣០ នាទី ដល់ ម៉ោង ០៩ : ៣០ នាទី**

- វិញ្ញាសាចំណេះដឹងទូទៅពាក់ព័ន្ធនឹងមុខងារសាធារណៈ ទៅតាមកម្រិតក្របខណ្ឌប្រភេទ កនិងខ សម្រាប់បេក្ខជនប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នទាំងប្រាំមួយ លើកលែងក្រសួងទេសចរណ៍
- វិញ្ញាសាចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យទេសចរណ៍ សម្រាប់បេក្ខជនប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងទេសចរណ៍ ក្នុងប្រភេទក្របខណ្ឌ ក

☞ **ម៉ោង ១០ : ០០ នាទី ដល់ ម៉ោង ១១ : ៣០ នាទី**

- វិញ្ញាសាភាសាអង់គ្លេសនិងកុំព្យូទ័រ សម្រាប់បេក្ខជនប្រឡងចូលក្របខណ្ឌក្រសួង ស្ថាប័ន ទាំងប្រាំពីរទៅតាមកម្រិតក្របខណ្ឌប្រភេទ កនិងខ។

**២- អំពីការបិទផ្សាយ**

- បញ្ជីឈ្មោះបេក្ខជនទាំងពីរភេទ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចូលរួមប្រឡងមានបិទផ្សាយនៅក្រសួង ស្ថាប័ន **ទាំងប្រាំពីរ ចាប់ពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ តទៅ។** បេក្ខជនទាំងពីរភេទមានសិទ្ធិតវ៉ាមកអនុគណៈកម្មការទទួលពាក្យនិងរៀបចំឯកសារនៅក្រសួងមុខងារសាធារណៈ ក្នុងករណី មិនមានឈ្មោះប្រឡង ឬ បញ្ហាផ្សេងៗ **ត្រឹមថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥។**
- ចំពោះប្លង់មណ្ឌលប្រឡង លេខបន្ទប់និងលេខតុ របស់បេក្ខជនទាំងពីរភេទនឹងធ្វើការបិទផ្សាយនៅវិទ្យាល័យព្រះស៊ីសុវត្ថិ **ថ្ងៃសៅរ៍ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោង ៧:៣០ នាទីព្រឹក តទៅ។**

អាស្រ័យហេតុនេះ សូម បេក្ខជន បេក្ខនារី ដែលមានឈ្មោះចូលរួមប្រឡងត្រូវត្រៀមលក្ខណៈជាមុននូវឯកសារដូចជា សលាកប័ត្រឯកត្តជន អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណសម្គាល់ខ្លួនសិស្ស និស្សិត ជាដើម។

បញ្ជាក់៖ គណៈកម្មការរៀបចំការប្រឡង មានសិទ្ធិកែប្រែសេចក្ដីជូនដំណឹងនេះ ក្នុងករណីចាំបាច់៕

**រដ្ឋលេខាធិការនិងជា**
**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**យូ ស៊ុនឡុង**